# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤
# និងទិសដៅឆ្នាំ២០២៥
# របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៥

- ឯកឧត្តម លោកជំទាវ ជាភ្ញៀវកិត្តិយស
- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា
- អង្គសន្និបាតទាំងមូលជាទីមេត្រី!

ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះវត្តមាន របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាភ្ញៀវកិត្តិយស ដែលអញ្ជើញមកពីព្រឹទ្ធសភា រដ្ឋសភា និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក៏ដូចជាថ្នាក់ដឹកនាំ ប្រធាន ស្ថានបេសកកម្មយើងនៅបរទេស មន្ត្រីរាជការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងលើកទិសដៅការងារឆ្នាំ២០២៥ នាព្រឹកនេះ។

ខ្ញុំសូមអរគុណ **លោកជំទាវ អ៊ាត សោភា** រដ្ឋលេខាធិការប្រចាំការ ដែលបានរាយការណ៍ដោយសង្ខេប រៀបរាប់ចំណុចសំខាន់ៗទាក់ទងនឹងសភាពការណ៍តំបន់ និងអន្តរជាតិ និងសមិទ្ធផលជាច្រើនដែលក្រសួងសម្រេចបានក្នុងឆ្នាំ២០២៤ កន្លងទៅ តាមរយៈការអនុវត្តការងារធំៗទាំង ៥ របស់ក្រសួង ដើម្បីការពារផលប្រយោជន៍ស្នូលរបស់ជាតិ និងលើកកម្ពស់កិត្យានុភាពរបស់កម្ពុជាក្នុងតំបន់ និងលើសកលលោក។ ខ្ញុំសូមអរគុណផងដែរ ដល់ក្រុមការងារនានាទាំងខាងផ្នែកខ្លឹមសារ ពិធីការ និងបច្ចេកទេស ដែលបានខិតខំប្រឹងប្រែង តាមភារកិច្ច មុខសញ្ញារបស់ខ្លួន

រៀបចំសន្និបាតប្រចាំឆ្នាំរបស់យើងបានទាន់ពេលវេលា ទោះបីជាស្របពេលគ្នានេះ ទាំងអស់គ្នាក៏ត្រូវខិតខំប្រឹងប្រែងបំពេញការងារប្រចាំថ្ងៃ រួមទាំងការរៀបចំទស្សនកិច្ចទៅក្រៅប្រទេស កិច្ចប្រជុំ ជំនួបនានា និងទទួលគណៈប្រតិភូបរទេសដ៏មមាញឹកយ៉ាងណាក៏ដោយ។

សមិទ្ធផលធំៗជាច្រើនក្នុងវិស័យការទូតដែលយើងសម្រេចបានមកទល់ពេលនេះ គឺពិតជាមិនអាចកាត់ផ្តាច់បាន ពីការចង្អុលបង្ហាញ និងពីការគាំទ្រយ៉ាងពេញទំហឹងរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ព្រមទាំងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធពីបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធទ្បើយ។ ក្នុងន័យនេះ ខ្ញុំសូមសម្តែងនូវអំណរគុណដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតចំពោះការគាំទ្រដែលមិនអាចកាត់ថ្លៃបានរបស់ **សម្តេចទាំងទ្វេ** ដែលជាមេដឹកនាំកំពូលរបស់កម្ពុជាយើង និងរបស់ថ្នាក់ដឹកនាំ មន្ត្រីទាំងឡាយនៃក្រសួង-ស្ថាប័ន ជាដៃគូទាំងអស់។ ខ្ញុំក៏សូមឆ្លៀតឱកាសនេះថ្លែងអំណរគុណដ៏ស្មោះចំពោះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ ចិន្តាសោភា** ដែលបានដឹកនាំ ចង្អុលចាត់ចែងការងាររបស់ក្រសួងជិតពេញមួយឆ្នាំ ២០២៤ កន្លងទៅ។

- ## ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា

មិនខុសពីឆ្នាំមុនៗឡើយ ដើម្បីបន្ថែមពុទ្ធិថ្មីៗដល់មន្ត្រីរបស់យើងក្នុងការបំពេញការងារប្រចាំថ្ងៃឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ យើងតែងតែអញ្ជើញវាគ្មិន មកធ្វើបទបង្ហាញលើប្រធានបទសំខាន់ៗសម្រាប់ការងារការទូត ជូនអង្គសន្និបាត។ ឆ្នាំនេះ យើងបានអញ្ជើញវាគ្មិនជាន់ខ្ពស់ ៣រូបគឺ (១) ឯកឧត្តម **ជា វុទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលនឹងធ្វើបទបង្ហាញស្តីពីកាលានុវត្តភាពវិនិយោគនៅកម្ពុជា (២) ឯកឧត្តម **នី ផល្លី** រដ្ឋលេខាធិការក្រសួងទេសចរណ៍ បានអញ្ជើញមកធ្វើបទបង្ហាញស្តីពីយុទ្ធសាស្ត្រជំរុញវិស័យទេសចរណ៍កម្ពុជា និង (៣) ឯកឧត្តម **ប្រាក់ ផល្លា** រដ្ឋលេខាធិការ ក្រសួងការ

បរទេស និងសហប្រតិបត្តិការអន្តរជាតិ និង**លោកជំទាវ អាង ម៉ូនីកា** ជំនួយការផ្ទាល់របស់ខ្ញុំ នឹងធ្វើបទបង្ហាញស្តីពីការកសាងធនាគារទិន្នន័យអេឡិចត្រូនិច របៀបចូលរកព័ត៌មានក្នុងធនាគារទិន្នន័យ ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន/បញ្ញាសិប្បនិម្មិត សម្រាប់ជាជំនួយក្នុងការរៀបចំខ្លឹមសារឯកសារដោយសុវត្ថិភាព ដោយរក្សាការសម្ងាត់នៃឯកសារ និងពត៌មាន។ ប្រធានបទទាំងបី ខាងលើ មានសារៈសំខាន់ណាស់ ក្នុងបរិបទដែលកម្ពុជាមានសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ មានឱកាស និងលក្ខណៈសម្បត្តិពេញលេញ សម្រាប់ការទាក់ទាញវិនិយោគិន ទេសចរបរទេស មកវិនិយោគ និងទស្សនាកម្ពុជា រកទីផ្សារឱ្យផលិតផលខ្មែរ ក៏ដូចជាការត្រៀមខ្លួនឲ្យបានល្អ ដើម្បីទាញយកប្រយោជន៍ជាអតិបរិមា ពីបរិវត្តកម្ម យ៉ាងឆាប់រហ័សនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ពិសេស ក្នុងយុគសម័យបញ្ញាសិប្បនិម្មិត (AI)។ ការណ៍នេះ ក៏រួមចំណែកម៉្យាងក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា វឌ្ឍនភាពសង្គម និងម៉្យាងទៀតបង្កើនប្រសិទ្ធភាពការងារ។

នៅពេលរសៀលនេះ និងនៅថ្ងៃស្អែក ខ្ញុំនឹងដឹកនាំកិច្ចប្រជុំចង្អៀត ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង ឯកអគ្គរាជទូត តំណាងអចិន្ត្រៃយ៍ និងអគ្គកុងស៊ុលកម្ពុជានៅបរទេសទាំងអស់ ដើម្បីពិភាក្សាលើប្រធានបទសំខាន់ៗចំនួន ៤៖ (**ទី១**) ការប្រកួតប្រជែងខាងយុទ្ធសាស្ត្រភូមិសាស្ត្រនយោបាយនៃប្រទេសមហាអំណាច និងអំណាចកណ្តាល និងនិន្នាការធំៗនៃពិភពលោក (**ទី២**) បញ្ហាប្រឈម និងកាលានុវត្តភាព នៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយរវាងមហាអំណាច ចំពោះតំបន់អាស៊ី-ប៉ាស៊ីហ្វិក អាស៊ាន និងជាពិសេសកម្ពុជា (**ទី៣**) បញ្ហាប្រឈមចំពោះការធានាប្រសិទ្ធភាពក្នុងការបំពេញការទូតរបស់កម្ពុជា និងកំណែទម្រង់ចាំបាច់ និង (**ទី៤**) ការពិនិត្យកែសម្រួលការងារធំៗទាំង ៥ ដែលយើងបានប្រើប្រាស់ជាត្រីវិស័យសម្រាប់អនុវត្តអស់ពេលច្រើនឆ្នាំមកហើយ។ លទ្ធផលសំខាន់ៗនៃកិច្ចពិភាក្សាទាំងនេះ នឹងត្រូវបូកសរុបគោរពាយការណ៍ ជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងពិធីបិទសន្និបាត នៅព្រឹកថ្ងៃទី៥ ខែមីនា ដើម្បីទទួលបានមកវិញនូវអនុសាសន៍

ណែនាំដ៏ខ្ពង់ខ្ពស់បំផុត សម្រាប់កំណត់ទិសដៅការងារការទូតសម្រាប់ឆ្នាំ ២០២៥ និងបណ្ដាឆ្នាំទៅមុខទៀត។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា!

ដូចដែល**លោកជំទាវ អ៊ាត សោភា** បានលើកឡើងមុននេះ នៅឆ្នាំ២០២៤ ពិភពលោកបានវិវត្តកាន់តែលឿន ទៅក្នុងស្ថានភាពស្មុគស្មាញ ផុយស្រួយ គ្រោះថ្នាក់ និងមិនច្បាស់លាស់ ដោយសារការកើនឡើងនៃការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកវិទ្យាទំនើប រវាងមហាអំណាចធំៗ ជម្លោះប្រដាប់អាវុធ និងការលំបាកក្នុងការស្វែងរក និងធានាសន្តិភាពនៅក្នុងតំបន់ និងប្រទេសជាច្រើន និងការកើនឡើងនៃបញ្ហាសន្តិសុខមិនប្រពៃណី។ ទាំងនេះក៏បាននាំឱ្យមានការកើនឡើងនូវឧក្រិដ្ឋកម្មឆ្លងដែន អស្ថិរភាពនៃខ្សែប្រវាក់ផ្គត់ផ្គង់ ការកើនឡើងតម្លៃម្ហូបអាហារ និងប្រេងឥន្ធនៈ និងហានិភ័យនៃការបម្រែបម្រួលអាកាសធាតុ។ ភាពច្របូកច្របល់នៃសណ្តាប់ធ្នាប់អន្តរជាតិ ដែលកំពុងឃ្លាតចេញពីគន្លងច្បាប់អន្តរជាតិនេះ បាននាំដល់ការធ្លាក់ចុះនៃកិច្ចសហប្រតិបត្តិការពហុភាគី ការចុះខ្សោយនៃស្ថាប័នអភិបាលកិច្ចសកល និងការបាត់បង់ជំនឿទុកចិត្ត លើសកលភាវូបនីយកម្ម។

ទ្វីប និងតំបន់នីមួយៗ មានបញ្ហារៀងៗខ្លួន ទោះជាបញ្ហានោះពាក់ព័ន្ធនឹងសង្គ្រាមរវាងរដ្ឋនិងរដ្ឋ ឬរវាងក្រុមប្រដាប់អាវុធនានាក្នុងរដ្ឋ បញ្ហាពាក់ព័ន្ធនឹងវិបត្តិសេដ្ឋកិច្ច-សង្គម សាសនា យោធា-សន្តិសុខ បច្ចេកវិទ្យា ឬក៏ជាបញ្ហាដែលពាក់ព័ន្ធនឹងសង្គ្រាមពាណិជ្ជកម្ម និងបច្ចេកវិទ្យាក៏ដោយ។

ក្នុងប៉ុន្មានឆ្នាំតទៅមុខ ការប្រកួតប្រជែងខាងភូមិសាស្ត្រ នយោបាយ សេដ្ឋកិច្ច យុទ្ធសាស្ត្រ រវាងមហាអំណាចធំៗនៅលើលោក នឹងកំណត់អំពីការប្រែប្រួលនៃស្ថានការណ៍តំបន់ និងពិភពលោក ហើយក៏នឹងដាក់សម្ពាធដោយផ្ទាល់ ឬដោយប្រយោល លើប្រទេសអំណាចកណ្តាល ឬតូចតាច ដូចកម្ពុជាយើងជាមិនខាន។

តំបន់អាស៊ី-ប៉ាស៊ីហ្វិក របស់យើង នឹងនៅតែជាមជ្ឈមណ្ឌលនៃការដណ្ដើមឧត្តមភាព ឥទ្ធិពល និងផលប្រយោជន៍របស់មហាអំណាចធំ និងមធ្យម និងជាទីតាំងនៃភាពតានតឹងជាច្រើនដោយសារតែសារៈសំខាន់នៃតំបន់នេះ ទាំងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម យុទ្ធសាស្ត្រ នយោបាយ និងការតភ្ជាប់ ពិសេសខាងផ្លូវសមុទ្រ។ ស្ថិតនៅកណ្តាលនៃការលំបាក និងការប្រឈមដ៏មហាសាលទាំងនេះ តើកម្ពុជានឹងត្រូវដើរលើផ្លូវណា បត់បែនយ៉ាងដូចម្តេច ជំនះ គេចឧបសគ្គ និងអន្ទាក់ណាខ្លះ ឆក់យកឱកាសណា ហើយខិតខំប្រឹងប្រែងយ៉ាងណា លើវិស័យអ្វីខ្លះ និងតាមរបៀបណា ដើម្បីរក្សាការពារផលប្រយោជន៍គោលរបស់ជាតិយើង? ទាំងនេះជាសំណួរខ្លះ ដែលអង្គសន្និបាតរបស់យើងនឹងខិតខំជជីកសួរ ស្វែងយល់ រកហេតុផល រកវិធីដោះស្រាយ និងរកចម្លើយឲ្យបានក្នុងការពិគ្រោះ ពិភាក្សាគ្នារយៈពេល ពីរថ្ងៃនេះ។

- ## ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា!

ខណៈពេលដែលយើងខិតខំផ្តោតការយកចិត្តទុកដាក់លើកិច្ចការអន្តរជាតិដ៏ស្មុគស្មាញនេះ យើងក៏មិនត្រូវភ្លេចពីការដ្ឋានកំណែទម្រង់ស្ថាប័នទាំងក្នុងក្រសួង និងនៅតាមបណ្ដាស្ថានបេសកកម្មនៅបរទេសនោះដែរ។ កន្លងមក កំណែទម្រង់ផ្ទៃក្នុងបាននាំមកនូវផ្លែផ្កាជាច្រើនគួរជាទីមោទនៈ ដូចជា ការកែលម្អលក្ខខណ្ឌការងារ ការលើកកម្ពស់សមភាព ភាពថ្លៃថ្នូររបស់មន្ត្រី បុគ្គលិកយើង ការលើកកម្ពស់សមត្ថភាព វិជ្ជាជីវៈ ភាពសកម្ម និងស្មារតីស្នេហាជាតិ ព្រមទាំងបានគិតគូរដល់ការកែលម្អ ជីវភាពរបស់មន្ត្រី បុគ្គលិកយើងឱ្យបានសមរម្យ។ យ៉ាងណាក៏ដោយ ការធ្វើកំណែទម្រង់ទាំងនេះ ជាការងារដែលយើងត្រូវធ្វើជាប្រចាំ និងចេះបត់បែនទាំងខាងចំណេះដឹង ការក្ដាប់សភាពការណ៍ និងការយល់ដឹងពីការប្រឈមដែលត្រូវជំនះ ឱ្យស្របទៅតាមការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិន្នាការពិភពលោក។ យើងនឹងធ្វើការពិភាក្សា និងរិះរកវិធានការចាំបាច់នានា ដើម្បីប្រែក្លាយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអ្នកការទូតរបស់យើង ទៅជាសេនាធិការ

ពិតៗរបស់រាជរដ្ឋាភិបាល ដើម្បីដើរតួនាទីជាទ័ពជួរមុខលើសមរភូមិការទូត ក្នុងបេសកកម្មការពារប្រយោជន៍ប្រទេសជាតិ និងប្រជាជនយើងនៅលើឆាកអន្តរជាតិ។

- ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា!

កម្ពុជាយើងមានភព្វសំណាងធំណាស់ ដែលបុព្វបុរសរបស់យើងបានបន្សល់ទុកនូវកេរ្តិ៍មរតកវប្បធម៌ប្រវត្តិសាស្ត្រ និងអរិយធម៌ដ៏រុងរឿងតាំងពីសម័យអង្គរមកដល់សព្វថ្ងៃនេះ។ ក្នុងស្មារតីនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី និងក្រុមការងារការទូតសេដ្ឋកិច្ចដែលបានខិតខំស្រាវជ្រាវចងក្រងនូវសៀវភៅ ស្តីពីម្ហូបខ្មែរ ដែលបានទទួលរង្វាន់ ៤ ដង ក្នុងការ ប្រកួតប្រជែងសៀវភៅម្ហូបអាស៊ីនៅលើពិភពលោក។ ខ្ញុំសូមយកឱកាសដ៏ប្រពៃនេះ ប្រកាសចេញផ្សាយជាផ្លូវការ សៀវភៅ «កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ ២ (The Taste of Angkor II)»។ សៀវភៅនេះត្រូវបានធ្វើបច្ចុប្បន្នភាព និងមានបន្ថែមមុខម្ហូបកាន់តែច្រើន បន្ទាប់ពីសៀវភៅ «កេរដំណែលស្នាដៃម្ហូបខ្មែរ ភាគ១» របស់យើងបានបង្ហាញពីលក្ខណៈពិសេសដោយឡែក អំពីវប្បធម៌ដ៏រុងរឿងនៃមុខម្ហូបខ្មែរ ដែលមានអាយុកាលរាប់ពាន់ឆ្នាំមកហើយ ហើយស្ថិតក្នុងចំណោមវប្បធម៌មុខម្ហូបដែលមានវ័យចំណាស់បំផុតក្នុងពិភពលោក។

ខ្ញុំជឿជាក់ថា អង្គសន្និបាតរបស់យើងនឹងប្រព្រឹត្តទៅដោយភាពហ្មត់ចត់ និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយនឹងកិច្ចពិភាក្សាផុសផុល សកម្ម និងទទួលបានផ្លែផ្កាត្រចះត្រចង់។ ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ សូមប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ។

ខ្ញុំសូមប្រកាសបើក «**សន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**» ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**